# នីតិវិធីការពន្លូតកូន - ដោយការវះកាត់

## ការពន្លូតកូនដោយការវះកាត់ គឺជាវិធីមួយដែលអ្នកអាចបញ្ចប់ការមានផ្ទៃពោះដោយចេតនា

ជំហានដំបូង គឺត្រូវកំណត់ការណាត់ជួបសម្រាប់ការពិគ្រោះយោបល់ខាងវេជ្ជសាស្ត្រ។ ក្នុងអំឡុងពេលពិគ្រោះយោបល់នេះ វេជ្ជបណ្ឌិតនឹង៖

- បញ្ជាក់ថាតើនីតិវិធីនេះវាសមស្របសម្រាប់អ្នកឬក៏អត់
- ពន្យល់ពីដំណើរការនៃការពន្លូតកូនដោយការវះកាត់
- រៀបចំការធ្វើតេស្តអេកូ និងឈាមពេលណាមានតម្រូវការ
- ផ្តល់ឱ្យអ្នកនូវសំណុំបែបបទយល់ព្រមមួយដើម្បីចុះហត្ថលេខា ប្រសិនបើអ្នកបន្តទៅមុខ
- ធ្វើការរៀបចំការពន្លូតកូន។

នៅតាមគ្លីនិកមួយចំនួន នីតិវិធីការពន្លូតកូនកើតឡើងក្នុងថ្ងៃពិគ្រោះយោបល់ដូចគ្នា។ កន្លែងខ្លះទៀត គឺធ្វើឡើងនៅថ្ងៃផ្សេងទៀត។

## ការរៀបចំពន្លូតកូនដោយការវះកាត់

- កុំជក់បារី ពិសាអាហារ ឬផឹកភេសជ្ជៈ (សូម្បីតែទឹក) សម្រាប់រយៈពេលប្រហែលប្រាំមួយម៉ោងមុនពេលវះកាត់។ នេះគឺសម្រាប់សុវត្ថិភាពរបស់អ្នកនៅពេលអ្នកចាក់ថ្នាំស្ពឹក។
- រៀបគម្រោងទៅគ្លីនិកឱ្យបានមុនយ៉ាងហោចណាស់ពីរបីម៉ោង។
- យកមកជាមួយនូវ៖

  - ទូនាប់ដៃ
  - លិខិតអ្នកជំនាញត្រូវបញ្ជូនរបស់អ្នក (បើមានតម្រូវការ)
  - ប័ណ្ណកម្មវិធី Medicare របស់អ្នក
  - ប័ណ្ណថៃរក្សាសុខភាពរបស់អ្នក (ប្រសិនបើពាក់ព័ន្ធ) និង
  - អ្វីផ្សេងទៀតដែលគ្លីនិចបានស្នើសុំ។
- រៀបចំឱ្យមាននរណាម្នាក់ដើម្បីមកដឹកអ្នកទៅផ្ទះវិញ។

## ថ្នាំស្ពឹកសម្រាប់ការពន្លូតកូន

អាស្រ័យលើគ្លីនីក ការចាក់ថ្នាំស្ពឹកសន្លប់សម្រាប់នីតិវិធី អាចទាក់ទិននឹង៖

- ការចាក់ថ្នាំស្ពឹកឱ្យសន្លប់ - អ្នកមិនដឹងខ្លួនទេក្នុងអំឡុងពេលវះកាត់
- ដាក់ឧស្ម័នអុកស៊ីដ (nitrous oxide) - ដើម្បីឱ្យគេងតិចៗ (ដែលអ្នកនៅដឹងខ្លួន ប៉ុន្តែមានអារម្មណ៍ងងុយគេងដោយសារថ្នាំសណ្តំ និងស្ងប់ស្ងាត់)
- ការចាក់ថ្នាំស្ពឹកនៅនឹងកន្លែង - ការចាក់ថ្នាំស្ពឹកចូលទៅក្នុងកស្បូនរបស់អ្នក ដើម្បីធ្វើឱ្យកន្លែងនោះស្ពឹក ឬ
- ការចាក់ថ្នាំស្ពឹកនៅនឹងកន្លែង ដោយប្រើថ្នាំសណ្តំមានអារម្មណ៍ងងុយគេង។

VICTORIA State Government
Health and Human Services

## នីតិវិធីការពន្លូតកូនដោយការវះកាត់

នីតិវិធីពន្លូតកូនដោយការវះកាត់ភាគច្រើនត្រូវបានអនុវត្តដោយប្រើ 'ការបឺត (ការបូម) ចេញ' ហើយតាមធម្មតា វាចំណាយពេលតិចជាង១៥នាទី។

នីតិវិធីមានដូចខាងក្រោមនេះ៖

- កស្បូនរបស់អ្នក ត្រូវបានបើកពង្រីកជាលំដាប់។
- បន្ទាប់មក គេសឹកបំពង់ស្តើងមួយចូលទៅក្នុងស្បូនរបស់អ្នក។
- ការមានផ្ទៃពោះត្រូវបានយកចេញដោយការបឺតយ៉ាងថ្នមស្រាល។
- ឧបករណ៍មួយហៅថា ប្រដាប់កោស ត្រូវបានគេប្រើដើម្បីពិនិត្យថាតើស្បូនវានៅស្អាតទទេ។

## បន្ទាប់ពីការពន្លូតកូនដោយការវះកាត់

ដើម្បីកាត់បន្ថយហានិភ័យនៃការកើតមានជំងឺបៅឆ្លង សម្រាប់រយៈពេលពីរសប្តាហ៍បន្ទាប់ពីការវះកាត់របស់អ្នក (ឬពីរបីថ្ងៃក្រោយពេលឈប់ហូរឈាម)៖

- ងូតទឹកផ្កាឈូក ជំនួសការងូតទឹកក្នុងអាង
- ជៀសវាងការរួមភេទ
- ជៀសវាងការហែលទឹក
- ប្រើទ្រនាប់រដូវ ជំនួសឆ្នុកឃាត់ឈាមរដូវ។

## ពេលណាត្រូវស្វែងរកជំនួយបន្ទាន់វេជ្ជសាស្ត្រ បន្ទាប់ពីការពន្លូតកូន

អ្នកនឹងមានការណាត់ជួបតាមដានជាទៀងទាត់ពីរបីសប្តាហ៍ក្រោយមក ជាមួយវេជ្ជបណ្ឌិតរបស់អ្នក។

សូមទៅជួបគ្លីនិក វេជ្ជបណ្ឌិត ឬមន្ទីរសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យភ្លាមៗ ប្រសិនបើ៖

- ការហូរឈាមរបស់អ្នកកាន់តែធ្ងន់ធ្ងរ
- អ្នកមានគ្រុនក្តៅខ្លួន
- អ្នកការរមួលសាច់ដុំ ឬការឈឺចាប់ពោះ (ក្បាលពោះ) យ៉ាងធ្ងន់ធ្ងរ។

## ផលប៉ះពាល់បន្ទាប់បន្សំ និងផលវិបាកនៃការពន្លូតកូនដោយការវះកាត់

ផលវិបាកមានតិចតួច ប៉ុន្តែកើតឡើងក្នុងចំនួនប្រហែលបីភាគរយនៃការពន្លូតកូនដោយការវះកាត់។ ការពន្លូតកូនបានកើតឡើងក្នុងត្រីមាសទីមួយ ដែលការពន្លូតកូនដោយការវះកាត់ភាគច្រើន មានផលវិបាកតិចតួច។

**ផលវិបាកធ្ងន់ធ្ងរនៃការពន្លូតកូនដោយការវះកាត់គឺមិនធម្មតាទេ ប៉ុន្តែអាចរួមបញ្ចូលដូចខាងក្រោមនេះ៖**

| ផលវិបាក | រោគសញ្ញា ឬផលប៉ះពាល់បន្ទាប់បន្សំ | អ្វីដែលត្រូវធ្វើ |
|---|---|---|
| **ការហូរឈាម** (ការហូរឈាមយ៉ាងខ្លាំង អាចបង្ហាញថាការពន្លូតកូនមិនបានធ្វើពេញលេញ) | • ការហូរឈាមដែលអាចសើមជោគទ្រនាប់រដូវធំច្រើនជាងពីរ ក្នុងមួយម៉ោង អស់រយៈពេលជាងពីរម៉ោង<br>• ហូរចេញកំណកឈាមទំហំប៉ុនផ្លែក្រូចឆ្មារតូច<br>• មានអារម្មណ៍ខ្សោយ ឬខ្សោយចង់សន្លប់ | • ស្វែងរកការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រជាបន្ទាន់<br>• ហៅលេខ 000 សម្រាប់រថយន្តសង្គ្រោះបន្ទាន់ ឬទៅមន្ទីរសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យដែលនៅជិតអ្នកបំផុត (កុំបើកបរដោយខ្លួនឯង រៀបចំឱ្យនរណាម្នាក់ដឹកអ្នក)<br>• អាចតម្រូវការព្យាបាលដោយប្រើប្រដាប់បូមកោសសម្អាតស្បូន។<br>• អាចតម្រូវការចាក់បញ្ចូលឈាម (វាកម្រណាស់)។ |
| **ការកើតជំងឺបៅឆ្លង** | អាចកើតមាន៖<br>• ការឈឺចុករមួលក្រពើ ឬការឈឺចុកពោះ (ក្បាលពោះ) | • ស្វែងរកការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រជាបន្ទាន់<br>• ទៅជួបគ្លីនិក វេជ្ជបណ្ឌិត ឬមន្ទីរសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យរបស់អ្នកភ្លាមៗ ដើម្បីព្យាបាលដោយថ្នាំផ្សះ |

| ផលវិបាក | រោគសញ្ញា ឬផលប៉ះពាល់បន្ទាប់បន្សំ | អ្វីដែលត្រូវធ្វើ |
|---|---|---|
| | • ការហូរចេញវត្ថុរាវពីទ្វារមាសមិនប្រក្រតី<br>• គ្រុនក្តៅខ្លួន<br>• ការហូរឈាមយ៉ាងធ្ងន់ធ្ងរ<br>• នឿយហត់<br>• ចុះរាគ<br>• ការក្អួតចង្អោរ។ | |
| **ការរងរបួសដល់ស្បូន**<br>នេះគឺកម្រកើតមានណាស់ដោយហេតុថាការពន្លូតកូនដោយការវះកាត់ត្រូវបានធ្វើឡើងដោយវេជ្ជបណ្ឌិតវះកាត់ដែលមានបទពិសោធន៍ | • ត្រូវបានកំណត់អត្តសញ្ញាណដោយវេជ្ជបណ្ឌិតវះកាត់។ | • វានឹងត្រូវបានសម្គាល់ដឹង និងព្យាបាលភ្លាមៗដោយវេជ្ជបណ្ឌិតវះកាត់។ |
| **ការរងរបួសដល់ ឬការចុះខ្សោយនៃកស្បូន**<br>នេះគឺកម្រណាស់ពីព្រោះការពន្លូតកូនដោយការវះកាត់ត្រូវបានធ្វើឡើងដោយគ្រូពេទ្យវះកាត់ដែលមានបទពិសោធន៍ | • នេះអាចបណ្តាលឱ្យមានបញ្ហាក្នុងការមានផ្ទៃពោះនាពេលអនាគត។ | • ក្នុងអំឡុងពេលមានផ្ទៃពោះនាពេលអនាគត គ្រូពេទ្យជំនាញខាងរោគស្ត្រីនឹងផ្តល់ដំបូន្មាន។ |

## ព័ត៌មានបន្ថែម

តារាងព័ត៌នេះគឺជាតារាងព័ត៌មានមួយក្នុងចំណោមតារាងព័ត៌មានបី អំពីការពន្លូតកូនដែលមានដាក់នៅក្នុងសៀវភៅ Health Translations Directory។ សូមមើលផងដែរ:

- នីតិវិធីពន្លូតកូន - ដោយការប្រើថ្នាំពេទ្យ
- ការពន្លូតកូន។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ ក្រសួងសុខភាព និងសេវាកម្មមនុស្ស ខែមករា ឆ្នាំ២០១៩
អាចទទួលយកបាននៅតាមវ៉ិបសៃថ៍ <http://healthtranslations.vic.gov.au/>